In: 12-6-18

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ១៥៧ ព.ណ.ចបព.ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មការគ្រប់គ្រង និងវាយតម្លៃការប្រឡងជ្រើសរើស អ្នកតំណាងស្របច្បាប់ក្នុងការចុះបញ្ជីពាណិជ្ជកម្ម

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១.អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- បានឃើញប្រកាសលេខ ១៩១ ពណ.ចបព.ប្រក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម
- បានឃើញប្រកាសលេខ ២៥៨ ព.ណ ចបព.ប្រក ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការទទួលស្គាល់អ្នកតំណាងស្របច្បាប់ ក្នុងការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ឬ ឯកសារនាំចេញ-នាំចូល នៅក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម។

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

# សម្រេច

**ប្រការ ១**.- បង្កើតគណៈកម្មការគ្រប់គ្រង និងវាយតម្លៃការប្រឡងជ្រើសរើសអ្នកតំណាងស្របច្បាប់ក្នុងការចុះបញ្ជីពាណិជ្ជកម្ម ដែលមានសមាសភាពចូលរួមដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **សុខ សុភ័ក្ត្រ** | អនុរដ្ឋលេខាធិការទទួលបន្ទុក | ប្រធាន |
| ២. ឯកឧត្តម **កៅ កោសល** | អគ្គនាយកនៃអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម | អនុប្រធាន |
| ៣. លោក **ឱម តារាឫទ្ធិ** | ប្រធាននាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម | អនុប្រធាន |
| ៤. អនុប្រធាននាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មទាំងអស់ | | សមាជិក |

**ប្រការ ២**.- គណៈកម្មការគ្រប់គ្រង និងវាយតម្លៃការប្រឡងជ្រើសរើសអ្នកតំណាងស្របច្បាប់ក្នុងការចុះបញ្ជីពាណិជ្ជកម្ម មានភារៈកិច្ចដូចខាងក្រោម ៖

- រៀបចំ និងចេញវិញ្ញាសារប្រឡង
- រៀបចំបទបញ្ជាផ្ទៃក្នុងសម្រាប់មណ្ឌលប្រឡង
- រៀបចំសមាសភាពអនុរក្ស សម្រាប់ការប្រឡង (មេប្រយោគ)
- ត្រួតពិនិត្យការប្រឡង និងលទ្ធផលនៃការប្រឡង
- រៀបចំកំណែវិញ្ញាសារប្រឡង ដោយផ្តល់ចម្លើយនៃវិញ្ញាសារប្រឡង និងកំណត់ពិន្ទុសម្រាប់វិញ្ញាសារនិមួយៗ
- សុំសេចក្តីសម្រេចចុងក្រោយ ពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មពីសមាសភាពបេក្ខជន ដែលប្រឡងជាប់ជាស្ថាពរ។

**ប្រការ ៣**.- គណៈកម្មការប្រឡងមានសិទ្ធិបង្កើតលេខាធិការដ្ឋានប្រឡង ដែលមានទីចាត់ការនៅក្នុងនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម និងអាចចាត់តាំងមន្ត្រីមួយចំនួនជាជំនួយការ តាមការចាំបាច់។

**ប្រការ ៤**.- នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានមន្ទីរពាណិជ្ជកម្ម រាជធានី-ខេត្ត ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងពាណិជ្ជកម្មត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហ ១៣ រោច ខែ ភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន_សូរស័ក្តិ**

ចម្លងជូន៖
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ